ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**

# សេចក្ដីប្រកាសព័ត៌មាន

គណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ សូមជូនដំណឹងដល់សាធារណជន ឱ្យបានជ្រាបថា ក្រសួងការងារថៃបានជូនដំណឹងមកគណៈកម្មការផ្ដល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃថា ចន្លោះពីថ្ងៃទី២៤ ខែកក្កដា រហូតដល់ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧ នេះ ក្រសួងការងារថៃបាន៖

ទី១៖ ទទួលលិខិតស្វ័យប្រកាសពីនិយោជកថៃសរុបចំនួន ១៩៥,៦២៧និយោជក។

ទី២៖ ស្រង់ទិន្នន័យពលករបរទេស ដែលមិនទាន់ស្របច្បាប់ សរុបចំនួន ៦៩៤,៦២៩នាក់ ក្នុងនោះពលករកម្ពុជាមានចំនួន ២០៣,៧៣២នាក់ ដែលទាបជាងការប៉ាន់ប្រមាណរបស់ភាគីថៃ កាលពីខែកញ្ញា ឆ្នាំ២០១៦ កន្លងទៅ ដែលមានរហូតទៅដល់ជាង ៣០ម៉ឺននាក់។ ក្រៅពីប្រទេសកម្ពុជា មានពលករមីយ៉ាន់ម៉ាចំនួន ៤០២,៥៤២នាក់ និងឡាវចំនួន ៨៨,៣៦៥នាក់។ ជារួមតួលេខនេះគឺតិចជាងការរំពឹងទុករបស់ក្រសួងការងារថៃ។

ទី៣៖ ចាប់ពីថ្ងៃទី០៨ ខែសីហា ដល់ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧ គឺជាដំណាក់កាលមួយ សម្រាប់ពលករកម្ពុជា ដែលមិនទាន់ស្របច្បាប់ត្រូវទៅបង្ហាញខ្លួននៅការិយាល័យទាំង ៩៧កន្លែង របស់ភាគីថៃ ដើម្បីទទួលបានលិខិតបញ្ជាក់ពីក្រសួងការងារថៃ។

អាស្រ័យន័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

*រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧*